ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 03 / 2009
ម៉ោង (Time/Heure): 14:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 23 / 03 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អវតក/អជសដ

**Case File/Dossier No. 001/18-07-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **ធូ មណី**

កាលបរិច្ឆេទ: ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៩

ចំណាត់ថ្នាក់ឯកសារ: សម្ងាត់

---

## សំណើទៅការិយាល័យសហចៅក្រមស៊ើបអង្កេតទាក់ទងនឹងឯកសារ ដែលសាក្សី TC1 បានលើកឡើង

---

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Robert PETIT

**<u>ជនជាប់ចោទ</u>**
កាំង ហ្គេកអ៊ាវ ហៅ ឌុច

**<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE
ទី ស្រីនណា
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN

**<u>មេធាវីជនជាប់ចោទ</u>**
ការ សាវុត្ថ
François ROUX

00290457

E27

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ តាម "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច" ដែលអង្គបុរេជំនុំជម្រះបានសម្រេច និងប្រកាសនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ និងបញ្ចូលសេចក្តីសម្រេចនេះជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៨។

**កត់សម្គាល់ឃើញថា** នៅក្នុងអំឡុងពេលស្តាប់យកចម្លើយនៅការិយាល័យសហចៅក្រមស៊ើបអង្កេត សាក្សីTC1 លោក François Bizot បានលើកឡើងថា នៅឆ្នាំ១៩៧១ គាត់បានទទួលស្រោមសំបុត្រមួយច្បាប់ពីជនជាប់ចោទជូនចំពោះស្ថានទូតបារាំង ដែលក្នុងស្រោមសំបុត្រនោះ មានឯកសារមួយដែលមានចំណងជើងថា "កម្មវិធីនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា"[1]។

**ហេតុដូច្នេះ**

**សូមស្នើ** ការិយាល័យសហចៅក្រមស៊ើបអង្កេតធ្វើការចង្អុលបង្ហាញ ក្នុងរយៈពេល៣ថ្ងៃ ក្រោយពីបានទទួលសំណើនេះ ថាតើការិយាល័យនេះបានធ្វើការស៊ើបអង្កេតណាមួយ នៅក្រសួងការបរទេសរបស់ប្រទេសបារាំង ដើម្បីទទួលបានឯកសារដែលបានលើកឡើងខាងលើនេះដែរឬទេ ក្នុងករណីដែលការិយាល័យសហចៅក្រមស៊ើបអង្កេតមានឯកសារនេះ សូមការិយាល័យសហចៅក្រមស៊ើបអង្កេតបញ្ជូននូវច្បាប់ចម្លងនៃឯកសារនេះ ព្រមទាំងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធនឹងឯកសារនេះ មកអង្គជំនុំជម្រះសាលាដំបូង។

ភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • C E T C

និល ណុន

[1] ឯកសារ D40, ទំព័រ៦